# ឧបករណ៍សហគមន៍កាលីហ្វ័រញ៉ារបស់ខ្ញុំ

រៀងរាល់ដប់ឆ្នាំម្ដង បន្ទាប់ពីជំរឿនសហរដ្ឋអាមេរិក រដ្ឋកាលីហ្វ័រញ៉ាត្រូវតែគូសព្រំដែនមណ្ឌលសភា មណ្ឌលព្រឹទ្ធសភាតំណាងរដ្ឋ មណ្ឌលសភាតំណាងរដ្ឋ និងមណ្ឌលគណៈកម្មការសមភាពរបស់រដ្ឋសាជាថ្មីឡើងវិញ ដើម្បីឆ្លុះបញ្ចាំងអំពីទិន្នន័យប្រជាជនថ្មី។ ច្បាប់ស្ដីពីការបោះឆ្នោត Voters FIRST Act (ឆ្នាំ 2008) ផ្ដល់សិទ្ធិអំណាចដល់ពលរដ្ឋកាលីហ្វ័រញ៉ា ក្នុងការបង្កើតគណៈកម្មការកំណត់បែងចែកមណ្ឌលបោះឆ្នោតសម្រាប់ពលរដ្ឋកាលីហ្វ័រញ៉ា(California Citizens Redistricting Commission) (គណៈកម្មការ)។ គណៈកម្មការប្ដេជ្ញាចិត្តធ្វើការគូសផែនទីមណ្ឌលបោះឆ្នោតត្រឹមត្រូវ ដែលឆ្លុះបញ្ចាំងអំពីឧត្តមប្រយោជន៍របស់ពលរដ្ឋ មិនមែនរបស់អ្នកនយោបាយដែលកំពុងកាន់តំណែងនោះទេ។

**ប៉ុន្តែដើម្បីធ្វើបែបនេះបាន យើងត្រូវការមតិចូលរួមរបស់អ្នក! តាមរយៈឯកសារនេះ អ្នកអាចធានាបានថាគណៈកម្មការដឹងអំពីសហគមន៍របស់អ្នក ដោយធ្វើការប្រាប់គណៈកម្មការអំពីអ្វីដែលមានសារៈសំខាន់សម្រាប់អ្នក គូសផែនទីសហគមន៍របស់អ្នក និងដាក់បញ្ជូនមតិយោបល់ត្រឡប់អំពីសហគមន៍របស់អ្នកដោយផ្ទាល់ទៅកាន់គណៈកម្មការ។** អ្នកក៏អាចដាក់បញ្ជូនទម្រង់អេឡិចត្រូនិកនៃឯកសារជាក្រដាសនេះបានផងដែរ ដោយចូលទៅកាន់ DrawMyCACommunity.org។ មនុស្សគ្រប់រូបដែលរស់នៅក្នុងរដ្ឋកាលីហ្វ័រញ៉ាត្រូវបានអញ្ជើញឲ្យចូលរួម។ ថ្លៃសេវាប្រៃសណីយ៍ត្រូវបានទូទាត់ជូនដោយគណៈកម្មការដើម្បីបង្កើនការចូលរួម។ យើងទន្ទឹងរង់ចាំដំណឹងពីអ្នក!

## ចូលរួមនៅក្នុងដំណាក់កាលងាយៗចំនួន 3

|  |  |  |
|---|---|---|
| #1<br>ពិពណ៌នា<br>អំពីសហគមន៍របស់អ្នក | #2<br>គូស<br>សហគមន៍របស់អ្នក នៅលើផែនទី | #3<br>ផ្ញើ<br>សេចក្ដីថ្លែងការណ៍របស់អ្នកដោយផ្ទាល់ទៅកាន់ គណៈកម្មការ |

*<u>ឧទាហរណ៍ #1</u>*
*ខ្ញុំរស់នៅក្នុងតំបន់ដែលមានភាពខុសប្លែកមួយនៃទីក្រុង Farmers Branch ហៅថា Oak Knoll Valley។ ភូមិដ្ឋាននេះមានព្រំប្រទល់នៅចន្លោះផ្លូវ Highway 9 នៅផ្នែកខាងលិច និងទន្លេ Sunnyside River នៅផ្នែកខាងកើត។ ជាចម្បង វាជាតំបន់លំនៅដ្ឋាន ដែលតំបន់មួយចំនួនត្រូវបានកំណត់ជាតំបន់សម្រាប់ប្រើប្រាស់ក្នុងគោលបំណងពាណិជ្ជកម្ម និងចម្រុះ ជាពិសេសនៅតាមដងទន្លេ។ ភាសាដែលត្រូវបានគេនិយាយនៅ Oak Knoll Valley ជាចម្បងគឺភាសាអង់គ្លេសនិងអេស្ប៉ាញ ដោយអ្នកស្នាក់នៅមួយចំនួននិយាយភាសាវៀតណាម និងម៉ែនដារីន។ នៅទូទាំងតំបន់ទន្លេ ចាប់ពី Oak Knoll Valley គឺជាសហគមន៍ River Glen ដែលស្រដៀងនឹងសហគមន៍របស់យើងដែរព្រោះជាចម្បងវាគឺជាតំបន់លំនៅដ្ឋាន។ ពួកយើងស្ថិតនៅក្នុងមណ្ឌលសិក្សាធិការតែមួយ ហើយសិស្សនៅ Oak Knoll ទៅរៀននៅវិទ្យាល័យដែលស្ថិតនៅ River Glen។ វាជាការសមហេតុផលដែលតំបន់ពួកយើងត្រូវបានរួមបញ្ចូលនៅក្នុងមណ្ឌលនីតិបញ្ញត្តិ ឬសភាតែមួយ។*

*<u>ឧទាហរណ៍ #2</u>*
*ខ្ញុំរស់នៅ Bear City ដែលជាតំបន់ឧស្សាហកម្ម និងពាណិជ្ជកម្មមួយ នៅជិតផ្លូវ Highway 9 និងផ្លូវ 5-interstate freeway។ សហគមន៍របស់យើងគឺលាតសន្ធឹងចាប់ពីផ្លូវ Maple Street ដល់ផ្លូវ Oak Street និងចាប់ពី Green Drive និង Fork Road។ អ្នកស្នាក់នៅភាគច្រើនរស់នៅក្នុងអគារអាផាតមិនពហុគ្រួសារ ហើយពួកគេភាគច្រើនជាអ្នកចំណូលថ្មីនៅក្នុងតំបន់។ Bear City មានមណ្ឌលសិក្សាធិការរបស់ខ្លួន ហើយអ្នកស្នាក់នៅភាគច្រើនគឺនិយាយភាសាអង់គ្លេស។ សហគមន៍របស់យើងមិនគួរត្រូវបានរួមបញ្ចូលគ្នាជាមួយ River City ដែលស្ថិតនៅផ្នែកម្ខាងទៀតនៃផ្លូវ 5-interstate freeway នោះទេ។ River City បង្កើតឡើងដោយផ្ទះដែលមានតែមួយគ្រួសារ ហើយតម្រូវការរបស់ពួកគេគឺខុសគ្នាខ្លាំងពីពួកយើង។*

<u>ផែនទីគួរតែផ្ដល់ជូនពួកយើងនូវព័ត៌មានគ្រប់គ្រាន់ – ដូចជាផ្លូវ ផ្លូវ highway ឬលក្ខណៈធម្មជាតិដែលជាព្រំប្រទល់នៃសហគមន៍ – ដើម្បីអាចយល់បានថាតើសហគមន៍មានប្រយោជន៍របស់អ្នកស្ថិតនៅកន្លែងណា។</u> ពួកគេមិនទាមទារព័ត៌មានលម្អិតអ្វីលើសពីនោះទេ។